# តើនរណា
# ជាអ្នកបង្កើតខ្ញុំ?
# តើបង្កើតមកដើម្បីអ្វី?



# តើនរណា

## ជាអ្នកបង្កើតខ្ញុំ?
## តើបង្កើតមកដើម្បីអ្វី?



# តើនរណាជាអ្នកបង្កើតខ្ញុំ តើបង្កើតមកដើម្បីអ្វី?

## អ្វីគ្រប់យ៉ាងដែលមានបានបង្ហាញថា ត្រូវតែមានអ្នកដែលបង្កើត

- តើនរណាជាអ្នកដែលបានបង្កើតមេឃនិងផែនដី ព្រមទាំងភាវៈដ៏អស្ចារ្យទាំងឡាយដែលមនុស្សមិនអាចយល់អស់?
- តើនរណាជាអ្នកដែលបង្កើតប្រព័ន្ធដ៏ល្អឥតខ្ចោះ និងមានភាពសុក្រឹតបំផុតទាំងអស់នេះ?
- តើនរណាជាអ្នកដែលបានបង្កើតមនុស្ស ហើយធ្វើឱ្យពួកគេអាចស្តាប់ឮ អាចមើលឃើញ មានបញ្ញាញាណ និងមានសមត្ថភាពក្នុងការយល់ដឹង និងទទួលយកការពិត?
- តើអ្នកពន្យល់យ៉ាងដូចម្តេចចំពោះសុក្រឹតភាពនៅក្នុងសរពាង្គកាយរបស់អ្នក និងសត្វមានជីវិតដទៃទៀត? តើនរណាជាអ្នកបង្កើតនូវប្រព័ន្ធសរីរាង្គដ៏ល្អឥតខ្ចោះទាំងអស់នេះ?
- តើសាកលលោកដ៏អស្ចារ្យនេះ អាចដំណើរការទៅតាមប្រព័ន្ធប្រក្រតីភាពរបស់វាអស់រាប់ពាន់លានឆ្នាំបានយ៉ាងដូចម្តេចទៅ បើគ្មានអ្នកដែលមានអំណាចខ្លាំងអស្ចារ្យគ្រប់គ្រងដំណើរការរបស់វានោះ?
- តើនរណាជាអ្នកដែលបានបង្កើត និងគ្រប់គ្រងប្រព័ន្ធនៃដំណើរការសកលលោកទាំងមូលនេះ (ការរស់រានមានជីវិត ការស្លាប់ ការបន្តពូជ ពេលយប់ពេលថ្ងៃ និងការផ្លាស់ប្តូររដូវជាដើម)?
- តើសកលលោកនេះកើតឡើងដោយខ្លួនឯងឬ? ឬក៏កើតឡើងពីភាពទទេ? ឬក៏វាកើតឡើងដោយភាពចៃដន្យ?

- ហេតុអ្វីបានជាមនុស្សជឿលើវត្តមាននៃរបស់ដែលខ្លួនមិនបានមើលឃើញ ដូចជា បញ្ញា អារម្មណ៍ និងសេចក្តីស្រឡាញ់ជាដើម? តើមិនមែនដោយសារតែគេឃើញពីឥទ្ធិពលរបស់វាទេឬ? ដូច្នេះ តើមនុស្សអាចបដិសេធនូវវត្តមាននៃអ្នកដែលបង្កើតសាកលលោកនេះយ៉ាងដូចម្តេច ខណៈដែលពួកគេបានឃើញអំពីភាពធំធេងរបស់វា ដែលបានបង្ហាញយ៉ាងច្បាស់អំពីភាពអស្ចារ្យនៃការបង្កើតរបស់ទ្រង់ហើយនោះ?

ជាការពិតណាស់ គ្មាននរណាម្នាក់ទទួលយកនូវការនិយាយថា៖

មានផ្ទះមួយកើតឡើងដោយគ្មានអ្នកសាងសង់ ទេ!
ឬ
ធម្មជាតិ គឺជាអ្នកបង្កើតផ្ទះមួយនេះឡើងមក

ដូច្នេះ ហេតុដូចម្តេចបានជាមនុស្សមួយចំនួនជឿលើអ្នកដែលនិយាយថា៖ សាកលលោកដ៏អស្ចារ្យនេះកើតឡើងដោយគ្មានអ្នកបង្កើត? តើអ្នកដែលមានបញ្ញាញាណអាចទទួលយកការនិយាយអះអាងថា៖ សុក្រឹតភាពនៃការគ្រប់គ្រងសាកលលោកនេះកើតឡើងដោយចៃដន្យបានយ៉ាងដូចម្តេច?

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

“តើពួកគេត្រូវបានគេបង្កើតដោយគ្មានអ្នកបង្កើតឬ? ឬមួយពួកគេជាអ្នកដែលបង្កើតខ្លួនឯង? តើពួកគេបានបង្កើតមេឃជាច្រើនជាន់ និងផែនដីនេះឬ? ផ្ទុយទៅវិញ ពួកគេមិនជឿឡើយ”។

[គម្ពីរគួរអាន ៥២ : ៣៥-៣៦]

## ព្រះអល់ឡោះជាម្ចាស់ដ៏បរិសុទ្ធ និងខ្ពង់ខ្ពស់ជាទីបំផុត

**អល់ឡោះ** គឺជាព្រះជាម្ចាស់ និងជាអ្នកបង្កើតតែមួយអង្គគត់។ ទ្រង់មានព្រះនាម និងលក្ខណៈសម្បត្តិដ៏អស្ចារ្យជាច្រើនដែលបង្ហាញពីភាពពេញលេញល្អឥតខ្ចោះរបស់ទ្រង់។ ក្នុងចំណោមព្រះនាមទាំងនោះមានដូចជា អាល់ខលិក (ព្រះដែលបង្កើត) អាល់រ៉ហ៊ីម(ព្រះដ៏មេត្តាករុណា) អាល់រ៉ហ្សាក(ព្រះដែលប្រទានលាភសក្ការៈ) អាល់ការីម(ព្រះដ៏សប្បុរស) និង"**អល់ឡោះ**" ដែលជាព្រះនាមដ៏ល្បីល្បាញជាងគេបំផុតក្នុងចំណោមព្រះនាមរបស់ព្រះជាម្ចាស់ដ៏មហាខ្ពង់ខ្ពស់ និងមានអត្ថន័យថា ជាព្រះជាម្ចាស់ដែលសក្តិសមនឹងទទួលការគោរពសក្ការៈតែមួយអង្គគត់ ដោយគ្មានដៃគូរួមជាមួយទ្រង់ឡើយ។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

"អល់ឡោះជាព្រះជាម្ចាស់តែមួយអង្គគត់ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ ដែលរស់ជាអមតៈ ជាអ្នកគ្រប់គ្រងឡើយ។ ទ្រង់មិនព្រះថីនៈ(ងងុយគេង) ហើយក៏មិនផ្ទំដែរ។ អ្វីៗដែលមាននៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់។ គ្មានបុគ្គលណាម្នាក់ហ៊ានធ្វើអន្តរាគមន៍នៅចំពោះព្រះភក្ត្រទ្រង់ឡើយ លើកលែងតែមានការអនុញ្ញាតពីទ្រង់ប៉ុណ្ណោះ។ ទ្រង់ជ្រាបដឹងនូវអ្វីដែលមាននៅពីមុខ និងនៅពីក្រោយពួកគេ តែពួកគេមិនដឹងពីចំណេះដឹងរបស់ទ្រង់ឡើយ លើកលែងតែអ្វីដែលទ្រង់មានចេតនាប៉ុណ្ណោះ។ ហើយទម្រព្រះបាទ(គួរស៊ីយ៍)របស់ទ្រង់ទូលំទូលាយនៅលើមេឃជាច្រើនជាន់ និងផែនដី។ ការថែរក្សាវាទាំងពីរនេះមិនធ្វើឱ្យទ្រង់លំបាកឡើយ។ ហើយទ្រង់ខ្ពង់ខ្ពស់បំផុត ឧត្តុង្គឧត្តមបំផុត"។

[គម្ពីរគួរអាន ២ : ២៥៥]

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលទៀតថា៖

"ចូរអ្នក(មូហាំម៉ាត់)ពោលថា៖
អល់ឡោះ គឺជាព្រះជាម្ចាស់តែមួយអង្គគត់។
ព្រះអល់ឡោះ គឺជាអ្នកដែលត្រូវគេពឹងពាក់។
ទ្រង់មិនប្រសូតបុត្រ ហើយទ្រង់ក៏មិនត្រូវបានគេប្រសូតដែរ។
ហើយគ្មាននរណាម្នាក់ប្រៀបប្រដូចនឹងទ្រង់នោះឡើយ"។

[គម្ពីរគួរអាន ១១២ : ១-៤]

## លក្ខណៈសម្បត្តិ
## នៃព្រះអល់ឡោះជាម្ចាស់ដ៏បរិសុទ្ធ និងខ្ពង់ខ្ពស់ជាទីបំផុត

ព្រះអល់ឡោះជាម្ចាស់ គឺជាអ្នកដែលបានបង្កើតផែនដី និងធ្វើឲ្យវាមានសណ្ឋានសមស្របសម្រាប់ភាវៈទាំងឡាយរបស់ទ្រង់រស់នៅ។ ទ្រង់ជាអ្នកដែលបានបង្កើតមេឃ និងភាវៈដ៏អស្ចារ្យទាំងឡាយដែលមាននៅលើមេឃ។ ទ្រង់បានបង្កើតព្រះអាទិត្យ ព្រះចន្ទ ពេលយប់ ពេលថ្ងៃ និងកំណត់នូវប្រព័ន្ធរបស់វាដ៏ជាក់លាក់ដែលបង្ហាញពីអំណាចដ៏អស្ចារ្យរបស់ទ្រង់។

ព្រះជាម្ចាស់ គឺជាអ្នកដែលបានប្រទានខ្យល់ដង្ហើមដល់យើង ដែលយើងមិនអាចមានជីវិតបានដោយគ្មានវានោះឡើយ។ ទ្រង់ជាអ្នកដែលបានបញ្ចុះទឹកភ្លៀងមកកាន់យើង ហើយបានបង្កើតសមុទ្រ និងទន្លេសម្រាប់យើង។ ទ្រង់ជាអ្នកដែលចិញ្ចឹមយើងនៅពេលដែលយើងនៅជាគភ៌នៅក្នុងផ្ទៃម្ដាយ ដោយយើងគ្មានកម្លាំងពលំអ្វីសោះ។ ទ្រង់ជាអ្នកធ្វើឲ្យឈាមហូរក្នុងសរសៃឈាមរបស់យើង និងធ្វើឲ្យ បេះដូងលោតជាប់ជានិច្ច ចាប់ពីថ្ងៃចាប់កំណើត រហូតដល់ថ្ងៃស្លាប់។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

“ហើយព្រះអល់ឡោះបានបញ្ចេញពួកអ្នកពីផ្ទៃម្តាយរបស់ពួកអ្នក ខណៈដែលពួកអ្នកមិនដឹងអ្វីទាល់តែសោះ។ ហើយទ្រង់បានបង្កើតសម្រាប់ពួកអ្នកនូវការស្តាប់ឮ ការមើលឃើញ ហើយនិងបេះដូង(ចេះគិតពិចារណា) សង្ឃឹមថាពួកអ្នកនឹងដឹងគុណ”។

[គម្ពីរគួរអាន ១៦ : ៧៨]

## ព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈ ចាំបាច់ត្រូវមានលក្ខណៈសម្បត្តិល្អឥតខ្ចោះ

ព្រះជាម្ចាស់ដែលជាអ្នកបង្កើតយើងទ្រង់បានប្រទានសតិបញ្ញាដល់យើងដើម្បីឲ្យយើងអាចយល់ដឹងពីភាពអស្ចារ្យរបស់ទ្រង់។ ទ្រង់បានដាក់នៅក្នុងខ្លួនយើងនូវបុព្វធាតុ(ហ្វិតរ៉ោះ)ដែលបង្ហាញពីភាពល្អឥតខ្ចោះរបស់ទ្រង់។ ពិតណាស់ទ្រង់មិនអាចមានលក្ខណៈខ្វះខាត មិនពេញលេញ ឬគុណវិបត្តិអ្វីនោះឡើយ។

ការគោរពសក្ការៈចាំបាច់ត្រូវតែប្រណិបតន៍ចំពោះព្រះអល់ឡោះជាម្ចាស់តែមួយអង្គគត់ ព្រោះទ្រង់ជាព្រះជាម្ចាស់ដែលមានលក្ខណៈល្អឯក សក្តិសមនឹងទទួលការគោរពសក្ការៈ។ ចំណែកឯអ្វីផ្សេងក្រៅពីទ្រង់ គឺសុទ្ធតែមានលក្ខណៈខ្វះខាត មានគុណវិបត្តិ ត្រូវស្លាប់ និងវិនាសសាបសូន្យ មិនសក្តិសមនឹងទទួលបានការគោរពសក្ការៈឡើយ។

ព្រះដ៏ពិតប្រាកដដែលសក្តិសមនឹងទទួលបានការគោរពសក្ការៈមិនអាចជាមនុស្ស ឬរូបបដិមា ឬដើមឈើ ឬសត្វបានឡើយ។

មនុស្សដែលមានបញ្ញាមិនសក្តិសមនឹងគោរពសក្ការៈអ្វីមួយនោះឡើយ

លើកលែងតែរបស់នោះមានលក្ខណៈខ្ពង់ខ្ពស់ និងល្អឥតខ្ចោះប៉ុណ្ណោះ។ ដូច្នេះ តើគេអាចគោរពសក្ការៈចំពោះភាវៈមួយដែលមានលក្ខណៈទន់ខ្សោយជាងខ្លួនយ៉ាងដូចម្ដេច?

ព្រះជាម្ចាស់មិនអាចជាគភ៌នៅក្នុងផ្ទៃស្ត្រី រួចប្រសូតមកដូចទារកនោះឡើយ ហើយទ្រង់ក៏មិនអាចសុគតនោះដែរ។

ព្រះជាម្ចាស់ គឺជាអ្នកដែលបង្កើតសព្វភាវៈទាំងអស់ ហើយភាវៈទាំងអស់ស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងរបស់ទ្រង់។ ដូច្នេះ មនុស្សមិនអាចបង្កគ្រោះថ្នាក់ដល់ព្រះជាម្ចាស់នោះឡើយ ហើយក៏គ្មាននរណាម្នាក់អាចចងឆ្កាង ធ្វើទារុណកម្ម និងធ្វើឲ្យព្រះអង្គអាម៉ាស់នោះដែរ។

ព្រះជាម្ចាស់ គឺមិនចេះសម្មោសា(ភ្លេច) ក៏មិនផ្ទំ និងមិនសោយក្រយា (ទទួលទានអាហារ)ឡើយ។ ទ្រង់ជាព្រះដ៏ឧត្តុង្គឧត្តម មិនត្រូវការដៃគូ ឬបុត្រនោះឡើយ។ ជាការពិតណាស់ ព្រះជាម្ចាស់គឺមានលក្ខណៈសម្បត្តិដ៏អស្ចារ្យ ហើយទ្រង់មិនអាចមានតម្រូវការ ឬភាពខ្វះខាតជាដាច់ខាត។ រាល់កស្តុតាងទាំងឡាយដែលផ្ទុយនឹងភាពអស្ចារ្យរបស់ទ្រង់ ដែលត្រូវបានគេភ្ជាប់ទៅកាន់ព្យាការីទាំងឡាយ គឺជាកស្តុតាងដែលត្រូវបានគេកែប្រែ ហើយវាមិនមែនជាសារ(វ៉ាហ៊ី)ត្រឹមត្រូវដែលនាំមកដោយព្យាការីម៉ូសេ ព្យាការីយេស៊ូ និងព្យាការីដទៃទៀត(សូមសន្តិភាព និងពរជ័យកើតមានដល់ពួកលោក)នោះឡើយ ។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

"ឱមនុស្សទាំងឡាយ! គេបានលើកជាឧទាហរណ៍មួយ ដូច្នេះ ចូរពួកអ្នកស្ដាប់។ ពិតណាស់ ពួក(ព្រះនានា)ដែលពួកអ្នកកំពុងបួងសួងផ្សេងពីអល់ឡោះនោះ គឺពួកគេគ្មានសមត្ថភាពបង្កើតអ្វីមួយនោះឡើយ សូម្បីតែសត្វរុយមួយក្បាល

បើទោះបីជាពួកគេសហការគ្នាដើម្បីបង្កើតវាក៏ដោយ។ ហើយប្រសិនបើមានសត្វរុយមកទំស៊ីសំណែនរបស់ពួកគេនោះ ពួកវាក៏គ្មានសមត្ថភាពនឹងដេញឬបក់រុយនោះចេញបានដែរ។ ទាំងអ្នកដែលបួងសួងសុំ និងអ្នកដែលត្រូវគេបួងសួងសុំ(ព្រះនានា) គឺទន់ខ្សោយជាទីបំផុត។ ពួកគេមិនបានលើកតម្កើងព្រះអល់ឡោះជាម្ចាស់ឲ្យសក្តិសមនឹងឋានៈរបស់ទ្រង់ឡើយ។ ពិតប្រាដណាស់ព្រះអល់ឡោះខ្លាំងពូកែបំផុត មានអានុភាពបំផុត”។

[គម្ពីរគួរអាន ២២ : ៧៣-៧៤]

- តើសមហេតុផលដែរឬទេ ដែលព្រះជាម្ចាស់ទុកពួកយើងចោលដោយគ្មានសារ(វ៉ាហ៊ី)ណែនាំសម្រាប់យើងនោះ?
- តើសមហេតុផលដែរឬទេ ព្រះជាម្ចាស់ដែលប្រកបដោយបញ្ញាញាណទ្រង់បង្កើតភាវៈទាំងអស់នេះមកដោយគ្មានគោលបំណងអ្វីសោះ? តើទ្រង់បង្កើតមកដោយទទេៗ ឱ្យសោត់អណ្តែតគ្មានគោលដៅមែនទេ?
- តើសមហេតុផលដែរឬទេដែលថា អ្នកដែលបង្កើតយើងមកយ៉ាងរៀបរយ និងល្អឥតខ្ចោះ ហើយបានរចនាអ្វីៗដែលនៅលើមេឃ និងផែនដីសម្រាប់ទ្រទ្រង់ជីវិតយើង ប៉ុន្តែបែរជាគ្មានគោលបំណងអ្វី ឬមិនបានផ្តល់ចម្លើយដល់យើង ទុកឱ្យយើងច្របូកច្របល់ក្នុងចិត្តចំពោះសំណួរសំខាន់ៗ ដូចជាហេតុអ្វីបានជាយើងមកទីនេះ? តើមានអ្វីកើតឡើងបន្ទាប់ពីការស្លាប់? តើគោលបំណងនៃជីវិតយើងជាអ្វី?

ពុំដូច្នោះឡើយ។ ផ្ទុយទៅវិញ ព្រះអល់ឡោះជាម្ចាស់ទ្រង់បានបញ្ជូនអ្នកនាំសារជាច្រើនមកដើម្បីឲ្យយើងបានដឹងពីគោលបំណងនៃវត្តមានរបស់យើងនៅទីនេះ និងអ្វីដែលទ្រង់ចង់បានពីពួកយើង។

អល់ឡោះជាម្ចាស់បានបញ្ជូនអ្នកនាំសារជាច្រើនមកដើម្បីប្រាប់យើងថា ទ្រង់តែមួយអង្គគត់ជាអ្នកដែលសក្តិសមនឹងទទួលការគោរពសក្ការៈ និងដើម្បីឲ្យយើងដឹងពីរបៀបគោរពសក្ការៈចំពោះទ្រង់ ហើយក៏ដើម្បីផ្សព្វផ្សាយដល់យើងនូវបទបញ្ជា និងបម្រាមទាំងឡាយរបស់ទ្រង់ ព្រមទាំងបង្រៀនយើងនូវគុណតម្លៃនៃជីវិត។ បើកាលណាយើងគោរពប្រតិបត្តិតាម នោះជីវិតរបស់យើងនឹងប្រកបដោយសេចក្តីល្អ និងមានពរជ័យ។

ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ជូនអ្នកនាំសារជាច្រើនដូចជា ព្យាការីអ៊ីប្រាហ៊ីម ព្យាការីម៉ូសេ និងព្យាការីយេស៊ូ ហើយទ្រង់បានប្រទានដល់អ្នកនាំសារទាំងនេះនូវសញ្ញាភស្តុតាង និងអច្ឆរិយភាពជាច្រើនដែលបង្ហាញពីសច្ចភាពរបស់ពួកលោក ដើម្បីបញ្ជាក់ថាពួកលោកពិតជាត្រូវបានចាត់តាំងមកពីព្រះជាម្ចាស់។ ហើយអ្នកនាំសារចុងក្រោយបង្អស់នោះ គឺព្យាការីមូហាំម៉ាត់ (សូមសន្តិភាព និងពរជ័យកើតមានដល់លោក) ហើយអល់ឡោះជាម្ចាស់ក៏បានបញ្ចុះព្រះគម្ពីរគួរអានដ៏ឧត្តុង្គឧត្តមមកកាន់លោកផងដែរ។

បណ្តាអ្នកនាំសារទាំងអស់បានប្រាប់យើងយ៉ាងច្បាស់ថា ឆាកជីវិតនេះគឺជាការសាកល្បង ហើយជីវិតពិតនឹងមកដល់បន្ទាប់ពីស្លាប់។ ពួកលោកក៏បានប្រាប់យើងផងដែរថា មានឋានសួគ៌សម្រាប់អ្នកមានជំនឿដែលបានគោរពសក្ការៈចំពោះព្រះអល់ឡោះជាម្ចាស់តែមួយអង្គគត់ និងមានជំនឿចំពោះបណ្តាអ្នកនាំសារទាំងអស់ ហើយក៏មានឋាននរកផងដែរ ដែលទ្រង់បានត្រៀមទុកសម្រាប់ពួកប្រឆាំង

ដែលគោរពសក្ការៈព្រះផ្សេងក្រៅពីព្រះអល់ឡោះ ឬគោរពសក្ការៈអ្វីផ្សេងរួមជាមួយនឹងទ្រង់ ឬបដិសេធអ្នកនាំសារណាម្នាក់ក្នុងចំណោមបណ្ដាអ្នកនាំសាររបស់អល់ឡោះ។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

“ឱកូនចៅអាដាំ! ប្រសិនបើបណ្ដាអ្នកនាំសារក្នុងចំណោមពួកអ្នកពិតជាមកដល់ពួកអ្នកដោយពួកគេនិទានឱ្យពួកអ្នកស្ដាប់នូវបណ្ដាភស្ដុតាងរបស់យើងរួច ដូច្នេះ បើជនណាកោតខ្លាចអល់ឡោះ និងបានកែប្រែខ្លួននោះ គឺពួកគេគ្មានការភ័យខ្លាចឡើយ ហើយពួកគេក៏មិនព្រួយបារម្ភនោះដែរ។ រីឯពួកដែលបានបដិសេធនឹងបណ្ដាភស្ដុតាងរបស់យើង និងក្រអឺតក្រទមចំពោះវា ពួកទាំងនោះគឺជាពួកឋាននរក ដោយស្ថិតនៅក្នុងនោះជាអមតៈ”។

[គម្ពីរគួរអាន ៧ : ៣៥-៣៦]

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលទៀតថា៖

“តើពួកអ្នកគិតថា យើងបានបង្កើតពួកអ្នកមកគ្រាន់តែជាការលេងសើច ហើយនិងមិនត្រូវបានគេនាំត្រឡប់មកជួបយើងវិញ(ដើម្បីជំនុំជម្រះ)ឬ?”

[គម្ពីរគួរអាន ២៣ : ១១៥]

## ព្រះគម្ពីរគួរអាន

ព្រះគម្ពីរគួរអាន គឺជាព្រះបន្ទូលរបស់អល់ឡោះជាម្ចាស់ដែលទ្រង់បានបញ្ចុះទៅកាន់អ្នកនាំសារចុងក្រោយបង្អស់ គឺព្យាការីមូហាំម៉ាត់( សូមសន្តិភាព និងពរជ័យមានដល់លោក)។ វាគឺជាអច្ឆរិយភាពដ៏អស្ចារ្យបំផុតដែលបញ្ជាក់ពីសច្ចភាពនៃភាពជាព្យាការីរបស់លោក។ ព្រះគម្ពីរគួរអាន គឺជាគម្ពីរដែលផ្ទុកនូវបញ្ញត្តិច្បាប់ និងដំណឹងទាំងឡាយដ៏សច្ចៈ។ អល់ឡោះជាម្ចាស់បានឲ្យពួកដែលបដិសេធទាំងឡាយធ្វើការប្រឡងប្រជែង ដោយឱ្យពួកគេនាំមកនូវជំពូកមួយដែលដូចទៅនឹងគម្ពីរគួរអាននេះ ប៉ុន្តែពួកគេគ្មានសមត្ថភាពអាចធ្វើបានឡើយ ដោយសាររចនាបថដ៏ល្អឯក និងសោភ័ណ្ឌភាពនៃសំនួនពាក្យនៃគម្ពីរ។ គម្ពីរនេះផ្ទុកទៅដោយភស្តុតាងដ៏មានហេតុផលឡូហ្សិក(តក្កៈ) និងព័ត៌មានវិទ្យាសាស្ត្រ និងរឿងរ៉ាវអព្ភូតហេតុអស្ចារ្យជាច្រើនដែលបង្ហាញថា គម្ពីរនេះមិនអាចជាស្នាដៃរបស់មនុស្សណាម្នាក់នោះឡើយ។ ផ្ទុយទៅវិញ វាជាបន្ទូលរបស់ព្រះជាម្ចាស់។

## ហេតុអ្វីបានជាមានអ្នកនាំសារជាច្រើន ?

តាំងពីការកកើតជីវិតដំបូងមកម្ល៉េះ ព្រះអល់ឡោះជាម្ចាស់ទ្រង់បានបញ្ជូនអ្នកនាំសារជាច្រើនជាបន្តបន្ទាប់ដើម្បីអំពាវនាវមនុស្សទៅកាន់ទ្រង់និងផ្សព្វផ្សាយនូវបទបញ្ជា និងបម្រាមទាំងឡាយរបស់ទ្រង់ទៅដល់ពួកគេ។ ហើយការអំពាវនាវដ៏សំខាន់បំផុតរបស់អ្នកនាំសារទាំងអស់ គឺការអំពាវនាវទៅកាន់ការគោរពសក្ការៈចំពោះព្រះអល់ឡោះតែមួយអង្គគត់។ នៅពេលដែលប្រជាជាតិទាំងនោះចាប់ផ្តើមបោះបង់ ឬបំភ្លៃនូវអ្វីដែលអ្នកនាំសារបាននាំមក ព្រះអល់ឡោះជាម្ចាស់ទ្រង់បានចាត់តាំងអ្នកនាំសារម្នាក់ទៀតមកដើម្បីតំរែតម្រង់ផ្លូវ និងនាំមនុស្សត្រឡប់ទៅរក

បុព្វជំនឿពីកំណើតដ៏ស្អាតស្អំ(ហ្វិតរ៉ោះ)នៃការគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់តែមួយវិញ រហូតដល់ព្រះអល់ឡោះបានបញ្ចប់ការតែងតាំងអ្នកនាំសារទាំងឡាយត្រឹមអ្នកនាំសារមូហាំម៉ាត់(សូមសន្តិភាពនិងពរជ័យមានដល់លោក) ដែលលោកបាននាំមកនូវច្បាប់បញ្ញត្តិអមតៈ និងមានលក្ខណៈជាសាកលសម្រាប់មនុស្សលោកទូទៅរហូតដល់ថ្ងៃបរលោក។ វាជាច្បាប់បញ្ញត្តិដែលបំពេញបន្ថែម និងនិរាករណ៍ចោលនូវច្បាប់បញ្ញត្តិមុនៗ។ ព្រះអល់ឡោះជាម្ចាស់ទ្រង់បានធានាថែរក្សាច្បាប់បញ្ញត្តិនេះ និងសារនេះឲ្យនៅគង់វង្សរហូតដល់ថ្ងៃបរលោក។

ហេតុនេះ យើងជាជនមូស្លីមមានជំនឿចំពោះបណ្ដាអ្នកនាំសារទាំងអស់ និងបណ្ដាគម្ពីរមុនៗទាំងអស់(ដូចដែលព្រះអល់ឡោះជាម្ចាស់បានបង្គាប់ប្រើ)។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

“អ្នកនាំសារ(មូហាំម៉ាត់) មានជំនឿលើអ្វីដែលព្រះជាម្ចាស់របស់លោកបានបញ្ចុះមកឱ្យលោក ហើយបណ្ដាអ្នកមានជំនឿទាំងឡាយក៏ដូចគ្នាដែរ។ ពួកគេទាំងអស់មានជំនឿលើអល់ឡោះ បណ្ដាទេវៈ(ម៉ាឡាអ៊ីកាត់)របស់ទ្រង់បណ្ដាព្រះគម្ពីររបស់ទ្រង់ និងបណ្ដាអ្នកនាំសាររបស់ទ្រង់។ (ពួកគេបាននិយាយថា៖) ពួកយើងមិនបែងចែកអ្នកនាំសារណាម្នាក់ក្នុងចំណោមអ្នកនាំសារទាំងឡាយរបស់ទ្រង់នោះឡើយ។ ហើយពួកគេបានពោលថា៖ ពួកយើងបានឮហើយ និងប្រតិបត្តិតាមហើយ។ បពិត្រព្រះអល់ឡោះជាម្ចាស់នៃយើងខ្ញុំ! សូមទ្រង់មេត្តាអភ័យទោសដល់យើងខ្ញុំ។ ចំពោះទ្រង់តែមួយអង្គគត់ដែលជាកន្លែងវិលត្រឡប់”។

[គម្ពីរគួរអាន ២ : ២៨៥]

# បុគ្គលម្នាក់មិនអាចក្លាយជាអ្នកមានជំនឿឡើយ លុះត្រាតែគេមានជំនឿចំពោះអ្នកនាំសារទាំងអស់

ព្រះអល់ឡោះជាម្ចាស់ គឺជាអ្នកដែលបានបញ្ជូនអ្នកនាំសារទាំងឡាយ។ ជនណាដែលបដិសេធសាររបស់អ្នកនាំសារណាម្នាក់ គឺគេពិតជាបានបដិសេធអ្នកនាំសារទាំងអស់។ គ្មានបាបកម្មណាធំជាងការបដិសេធសាររបស់អល់ឡោះជាម្ចាស់នោះឡើយ។ ហេតុនេះ ដើម្បីបានចូលឋានសួគ៌ ចាំបាច់ត្រូវតែមានជំនឿចំពោះអ្នកនាំសារទាំងអស់។

ដូចនេះ មនុស្សគ្រប់រូបគឺចាំបាច់ត្រូវមានជំនឿលើអ្នកនាំសារទាំងឡាយរបស់អល់ឡោះជាម្ចាស់ ហើយការមានជំនឿបែបនេះមិនអាចសម្រេចបានឡើយ លុះត្រាតែគេមានជំនឿ និងប្រតិបត្តិតាមអ្នកនាំសារចុងក្រោយបង្អស់ គឺព្យាការីមូហាំម៉ាត់( សូមសន្តិភាពកើតមានដល់លោក )។

ព្រះអល់ឡោះបានលើកឡើងនៅក្នុងព្រះគម្ពីរគួរអានថា ប្រាកដណាស់ ជនណាដែលបដិសេធ មិនមានជំនឿលើអ្នកនាំសារណាមួយរបស់អល់ឡោះ នោះគេគឺជាអ្នកដែលគ្មានជំនឿនឹងអល់ឡោះ និងបដិសេធសាររបស់ទ្រង់។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

“ពិតប្រាកដណាស់ ពួកដែលប្រឆាំងនឹងអល់ឡោះ និងបណ្ដាអ្នកនាំសាររបស់ទ្រង់ ហើយពួកគេចង់បែងចែករវាងអល់ឡោះ និងបណ្ដាអ្នកនាំសាររបស់ទ្រង់ ហើយពួកគេនិយាយថា៖ ពួកយើងមានជំនឿលើអ្នកនាំសារមួយចំនួន និងបដិសេធមួយចំនួនទៀត ហើយពួកគេចង់ជ្រើសរើសយកមាគ៌ាមួយរវាងរឿងនោះ (មានជំនឿ និងគ្មានជំនឿ) ពួកទាំងនោះ គឺជាពួកដែលប្រឆាំងយ៉ាងពិតប្រាកដ”។ [គម្ពីរគួរអាន ៤ : ១៥០-១៥១]

## តើអ៊ីស្លាមជាអ្វី?

អ៊ីស្លាម គឺជាការប្រគល់ខ្លួនចំពោះព្រះអល់ឡោះជាម្ចាស់ ដោយទទួលស្គាល់នូវភាពជាព្រះជាម្ចាស់តែមួយអង្គគត់របស់ទ្រង់ ដោយគោរពប្រតិបត្តិតាមបង្គាប់របស់ទ្រង់ និងអនុវត្តតាមច្បាប់បញ្ញត្តិរបស់ទ្រង់ដោយការពេញចិត្ត។

ពិតណាស់ ព្រះអល់ឡោះជាម្ចាស់ទ្រង់បានបញ្ជូនអ្នកនាំសារទាំងឡាយដើម្បីពាំនាំមកនូវសារតែមួយគត់គឺ អំពាវនាវទៅកាន់ការគោរពសក្ការៈចំពោះព្រះអល់ឡោះជាម្ចាស់តែមួយអង្គគត់ដោយគ្មានដៃគូរួមជាមួយទ្រង់ឡើយ។

អ៊ីស្លាម គឺជាសាសនានៃបណ្ដាព្យាការីទាំងអស់។ ការអំពាវនាវនៃព្យាការីទាំងអស់គឺតែមួយ ប៉ុន្តែច្បាប់បញ្ញត្តិរបស់ពួកលោកមានលក្ខណៈខុសៗគ្នា។ ជនមូស្លីម ឬអ្នកកាន់សាសនាអ៊ីស្លាមនាពេលបច្ចុប្បន្ននេះ គឺជាក្រុមតែមួយគត់ដែលនៅតែប្រកាន់ខ្ជាប់នឹងសាសនាត្រឹមត្រូវដែលព្យាការីទាំងអស់បាននាំមក។ សារអ៊ីស្លាមនៅក្នុងសម័យកាលបច្ចុប្បន្ននេះ គឺជាសេចក្ដីពិត ព្រោះព្រះជាម្ចាស់ដែលបានបញ្ជូនព្យាការីអ៊ីព្រាហ៊ីម ព្យាការីម៉ូសេ និងព្យាការីយេស៊ូ គឺជាព្រះជាម្ចាស់តែមួយអង្គគត់ដែលបានបញ្ជូនអ្នកនាំសារចុងក្រោយ គឺព្យាការីមូហាំម៉ាត់។ ហើយច្បាប់បញ្ញត្តិអ៊ីស្លាម គឺបាននាំមកដើម្បីនិរាករណ៍នូវច្បាប់បញ្ញត្តិមុនៗ។

ជាការពិតណាស់ សាសនាទាំងអស់ដែលមនុស្សគោរពសក្ការៈសព្វថ្ងៃ (ក្រៅពីសាសនាអ៊ីស្លាម) គឺជាសាសនាដែលបង្កើតឡើងដោយមនុស្ស ឬជាសាសនានៃព្រះអល់ឡោះជាម្ចាស់ តែក្រោយមកក៏ត្រូវបានមនុស្សកែប្រែដោយដៃរបស់ពួកគេ ដែលបណ្ដាលឱ្យមានការលាយឡំគ្នានឹងអបិយជំនឿ និងទេវកថាដែលបានបន្តពីមួយជំនាន់ទៅមួយជំនាន់ ហើយបញ្ចូលនូវគំនិតរបស់មនុស្ស។ ចំណែកឯគោលជំនឿរបស់អ្នកមូស្លីមវិញ គឺជាគោលជំនឿតែមួយដែលមានភាព

ច្បាស់លាស់ និងមិនមានការកែប្រែនោះឡើយ។ សូមអ្នកក្រឡេកមើលទៅកាន់ព្រះគម្ពីរគួរអាន ដែលជាព្រះគម្ពីរតែមួយគត់នៅគ្រប់ប្រទេសដែលកាន់សាសនាអ៊ីស្លាមទាំងអស់។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

“ចូរអ្នក(មូហាំម៉ាត់)ពោលថា៖ ពួកយើងមានជំនឿលើអល់ឡោះ និងអ្វីដែលគេបានបញ្ចុះមកលើពួកយើង និងអ្វីដែលគេបានបញ្ចុះទៅលើព្យាការីអាប្រាហាំ អ៊ីស្មាអេល អ៊ីសាក់ យ៉ាកុប និងបណ្ដាកូនចៅរបស់លោក ហើយនិងអ្វីដែលគេបានផ្ដល់ឱ្យព្យាការីម៉ូសេ ព្យការីយេស៊ូ និងបណ្ដាព្យាការី(ដែលត្រូវបានចាត់តាំង)ពីព្រះជាម្ចាស់របស់ពួកគេ។ ពួកយើងមិនបែងចែកនរណាម្នាក់ក្នុងចំណោមពួកគេឡើយ ហើយពួកយើង គឺជាអ្នកប្រគល់ខ្លួនចំពោះទ្រង់។ ហើយជនណាដែលស្វែងរកសាសនាផ្សេងក្រៅពីសាសនាឥស្លាម អល់ឡោះជាម្ចាស់នឹងមិនទទួលយក(ទង្វើល្អ)ពីគេឡើយ។ ហើយនៅថ្ងៃបរលោក រូបគេនឹងស្ថិតក្នុងចំណោមពួកដែលខាតបង់”។ [គម្ពីរគួរអាន ៣ : ៨៤-៨៥]

## តើជនមូស្លីមមានជំនឿបែបណាចំពោះព្យាការីយេស៊ូ( សូមសន្តិភាពកើតមានដល់លោក ) ?

តើអ្នកដឹងទេថា អ្នកមូស្លីមចាំបាច់ត្រូវមានជំនឿចំពោះព្យាការីយេស៊ូ ឬអ៊ីសា ហើយត្រូវស្រឡាញ់ និងលើកតម្កើងចំពោះលោក ព្រមទាំងមានជំនឿលើសាររបស់លោក ជាសារដែលអំពាវនាវទៅកាន់ការគោរពសក្ការៈចំពោះព្រះអល់ឡោះជាម្ចាស់តែមួយអង្គគត់ដោយគ្មានដៃគូរួមជាមួយទ្រង់ឡើយ។ ជនមូស្លីមទាំងឡាយជឿថា យេស៊ូ និង មូហាំម៉ាត់( សូមសន្តិភាពកើតមានដល់លោកទាំងពីរ ) គឺជាព្យាការីរបស់

អល់ឡោះ ហើយលោកទាំងពីរត្រូវបានបញ្ជូនមកដើម្បីចង្អុលបង្ហាញមនុស្សទៅកាន់មាគ៌ារបស់ទ្រង់ ដែលជាមាគ៌ាឆ្ពោះទៅកាន់ឋានសួគ៌។

អ្នកមូស្លីមជឿថា ព្យាការីយេស៊ូ(សូមសន្តិភាពកើតមានដល់លោក) គឺជាអ្នកនាំសារដ៏ឧត្តុង្គឧត្តមម្នាក់ក្នុងចំណោមអ្នកនាំសារដែលអល់ឡោះជាម្ចាស់ទ្រង់បានបញ្ជូនមក។ ហើយជឿថា លោកបានប្រសូតមកដោយភាពអច្ឆរិយៈបំផុត។ អល់ឡោះជាម្ចាស់ទ្រង់បានប្រាប់យើងនៅក្នុងគម្ពីរគួរអានថា៖ ជាការពិតណាស់ ទ្រង់បានបង្កើតព្យាការីយេស៊ូដោយគ្មានឪពុក ដូចដែលទ្រង់បានបង្កើតព្យាការីអាដាំដោយគ្មានឪពុកនិងម្តាយដែរ ព្រោះអល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

អ្នកមូស្លីមជឿថា ព្យាការីយេស៊ូមិនមែនជាព្រះ ឬជាបុត្ររបស់ព្រះឡើយ ហើយលោកក៏មិនត្រូវបានគេឆ្កាងនោះដែរ។ ផ្ទុយទៅវិញ លោកនៅមានជីវិតនៅឡើយ។ អល់ឡោះជាម្ចាស់បានលើកលោកទៅកាន់ទ្រង់ដើម្បីឲ្យលោកចុះមកកាន់ផែនដីវិញនាសម័យកាលចុងក្រោយ(មុនថ្ងៃបរលោកមកដល់)ក្នុងនាមជាអ្នកដឹកនាំដ៏យុត្តិធម៌ម្នាក់ ហើយលោកនឹងរស់នៅជាមួយអ្នកមូស្លីមទាំងឡាយ ពីព្រោះអ្នកមូស្លីម ពួកគេមានជំនឿចំពោះអល់ឡោះជាម្ចាស់តែមួយអង្គគត់ ដូចអ្វីដែលព្យាការីយេស៊ូ ព្រមទាំងអ្នកនាំសារទាំងអស់បាននាំមក។

ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានប្រាប់យើងនៅក្នុងគម្ពីរគួរអានថា ពិតណាស់ សាររបស់ព្យាការីយេស៊ូត្រូវបានគ្រីស្តបរិស័ទទាំងឡាយកែប្រែ។ ហើយមានពួកជ្រុលនិយមវង្វេងជាច្រើនបានកែប្រែគម្ពីរសម្ព័ន្ធមេត្រីថ្មី ឬគម្ពីរអ៊ិញជីល ហើយពួកគេបានបន្ថែមនូវអត្ថបទជាច្រើនដែលព្យាការីយេស៊ូមិនបានមានប្រសាសន៍។ រឿងនេះគឺត្រូវបានបញ្ជាក់ដោយវត្តមាននៃគម្ពីរសម្ព័ន្ធមេត្រីថ្មីជាច្រើនត្រូវបានកែប្រែ និងមានភាពផ្ទុយគ្នាជាច្រើននៅក្នុងនោះ។

ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានប្រាប់យើងថា ព្យាការីយេស៊ូ លោកគោរពសក្ការៈចំពោះអល់ឡោះដែលជាព្រះជាម្ចាស់របស់លោក ហើយលោកមិនបានសុំឱ្យនរណាម្នាក់គោរពសក្ការៈចំពោះលោកឡើយ។ ផ្ទុយទៅវិញ លោកបានបង្គាប់ប្រើក្រុមរបស់លោកឲ្យគោរពសក្ការៈចំពោះព្រះជាម្ចាស់ដែលជាអ្នកបង្កើតរូបលោក។ ក៏ប៉ុន្តែបិសាចសាតាំងបានធ្វើឱ្យគ្រឹស្តបរិស័ទទាំងឡាយគោរពសក្ការៈចំពោះព្យាការីយេស៊ូទៅវិញ។ អល់ឡោះជាម្ចាស់ក៏បានប្រាប់យើងនៅក្នុងគម្ពីរគួរអានដែរថា ទ្រង់នឹងមិនអត់ទោសឱ្យជនណាម្នាក់ដែលគោរពសក្ការៈអ្នកផ្សេងក្រៅពីអល់ឡោះនោះឡើយ។ ហើយនៅថ្ងៃបរលោក ព្យាការីយេស៊ូនឹងដោះខ្លួនចេញពីអ្នកទាំងឡាយដែលបានគោរពសក្ការៈចំពោះលោក ដោយលោកនឹងនិយាយទៅកាន់ពួកគេថា៖ ខ្ញុំបានបង្គាប់ប្រើពួកអ្នកឱ្យគោរពសក្ការៈព្រះជាម្ចាស់ដែលជាអ្នកបង្កើតប៉ុណ្ណោះ ហើយខ្ញុំមិនបានសុំឱ្យពួកអ្នកគោរពសក្ការៈខ្ញុំឡើយ។ ក្នុងចំណោមភស្តុតាងដែលបញ្ជាក់ដូចនេះ គឺបន្ទូលរបស់អល់ឡោះជាម្ចាស់ដែលទ្រង់បានមានបន្ទូលថា៖

“ឱពួកគម្ពីរជន! ចូរពួកអ្នកកុំពន្លើសក្នុងសាសនារបស់ពួកអ្នក ហើយចូរពួកអ្នកកុំនិយាយពីអល់ឡោះជាម្ចាស់ក្រៅពីការពិតឱ្យសោះ។ តាមពិត យេស៊ូគ្រឹស្តកូនប្រុសរបស់នាងម៉ារី គឺជាអ្នកនាំសាររបស់អល់ឡោះ ហើយ(ទ្រង់បានបង្កើតពី)ពាក្យបន្ទូលរបស់ទ្រង់ដែលបានបញ្ជូនវាទៅកាន់នាងម៉ារី និងជាវិញ្ញាណពីទ្រង់(តាមយៈទេវៈកាព្រីយ៉ែល)។ ដូច្នេះ ចូរពួកអ្នកមានជំនឿលើអល់ឡោះ និងបណ្ដាអ្នកនាំសាររបស់ទ្រង់ចុះ ហើយកុំនិយាយថា បី(ព្រះត្រីឯក)។ ចូរពួកអ្នកឈប់និយាយពាក្យនេះ វាជាការប្រសើរសម្រាប់ពួកអ្នក។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់គឺជាព្រះតែមួយអង្គគត់។ ព្រះអង្គមានភាពស្អាតស្អំអំពីការមានបុត្រ។

អ្វីៗទាំងអស់ដែលមាននៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលមាននៅលើផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់។ គ្រប់គ្រាន់ហើយដែលអល់ឡោះជាអ្នកគ្រប់គ្រង”។

[គម្ពីរគួរអាន ៤ : ១៧១]

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលទៀតថា៖

“ហើយចូរចងចាំ នៅពេលដែលអល់ឡោះបានសួរថា៖ ឱយេស៊ូកូនប្រុសរបស់នាងម៉ារី! តើអ្នកឬដែលបាននិយាយទៅកាន់មនុស្សលោកថា៖ ចូរពួកអ្នកយកខ្ញុំ និងម្តាយរបស់ខ្ញុំធ្វើជាព្រះជាម្ចាស់ពីរក្រៅពីអល់ឡោះនោះ? លោកបានឆ្លើយតបថា៖ ព្រះអង្គមហាស្អាតស្អំ! មិនសក្តិសមទេសម្រាប់ទូលបង្គំក្នុងការនិយាយនូវអ្វីដែលពុំមែនជាការពិតសម្រាប់ទូលបង្គំនោះ។ ប្រសិនបើទូលបង្គំបាននិយាយបែបនេះមែន ទ្រង់ប្រាកដជាបានជ្រាបវាជាមិនខាន។ ទ្រង់ជ្រាបនូវអ្វីដែលមាននៅក្នុងខ្លួនទូលបង្គំ តែទូលបង្គំមិនអាចដឹងនូវអ្វីដែលមាននៅក្នុងខ្លួនទ្រង់ឡើយ។ ពិតប្រាកដណាស់ ទ្រង់តែមួយអង្គគត់ ដែលដឹងនូវប្រការអាថ៌កំបាំងទាំងឡាយបំផុត”។ [គម្ពីរគួរអាន ៥ : ១១៦]

ជនណាដែលចង់ទទួលបានសេចក្តីសង្គ្រោះនៅថ្ងៃបរលោក ចាំបាច់លើគេត្រូវចូលកាន់សាសនាអ៊ីស្លាម និងធ្វើតាមមាគ៌ារបស់ព្យាការីមូហាំម៉ាត់(សូមសន្តិភាព និងពរជ័យកើតមានដល់លោក)។

ក្នុងចំណោមសេចក្តីពិតមួយដែលបណ្តាព្យាការី និងអ្នកនាំសារទាំងអស់ (សូមសន្តិភាព និងពរជ័យកើតមានដល់ពួកលោក)បានឯកភាពគ្នានោះ គឺថា នៅថ្ងៃបរលោក មានតែជនមូស្លីមដែលមានជំនឿចំពោះព្រះអល់ឡោះជាម្ចាស់ មិនគោរពសក្ការៈអ្នកផ្សេងរួមនឹងទ្រង់ ហើយមានជំនឿលើអ្នកនាំសារទាំងអស់ប៉ុណ្ណោះ ទើបអាចទទួលបានសេចក្តីសង្គ្រោះ។ ដូច្នេះ អ្នកដែលរស់នៅសម័យកាល

ព្យាការីម៉ូសេ ហើយមានជំនឿចំពោះលោក និងដើរតាមការបង្រៀនរបស់លោក អ្នកទាំងនោះ គឺជាអ្នកមូស្លីម និងជាអ្នកមានជំនឿដ៏សុចរិត។ ក៏ប៉ុន្តែ បន្ទាប់ពីអល់ឡោះជាម្ចាស់ទ្រង់បានចាត់តាំងព្យាការីយេស៊ូ នោះអ្នកដែលដើរតាមព្យាការីម៉ូសេត្រូវតែមានជំនឿលើព្យាការីយេស៊ូ និងដើរតាមលោក។ ដូច្នេះ ជនណាដែលមានជំនឿលើព្យាការីយេស៊ូ អ្នកទាំងនោះ គឺជាជនមូស្លីមដ៏សុចរិត។ ក៏ប៉ុន្តែ ជនណាដែលបដិសេធមិនមានជំនឿលើព្យាការីយេស៊ូ ហើយនិយាយថា ខ្ញុំនឹងនៅតែប្រកាន់ខ្ជាប់នឹងសាសនារបស់ព្យាការីម៉ូសេ នោះគេមិនមែនជាអ្នកមានជំនឿឡើយ ព្រោះគេបានបដិសេធនឹងព្យាការីម្នាក់ដែលអល់ឡោះជាម្ចាស់ទ្រង់បានបញ្ជូនមក។ បន្ទាប់មកក្រោយពេលដែលអល់ឡោះបានបញ្ជូនអ្នកនាំសារចុងក្រោយ គឺព្យាការីមូហាំម៉ាត់។ មនុស្សគ្រប់រូបចាំបាច់ត្រូវតែមានជំនឿលើលោក ព្រោះព្រះជាម្ចាស់ដែលបានបញ្ជូនព្យាការីម៉ូសេ និងព្យាការីយេស៊ូ គឺជាព្រះជាម្ចាស់តែមួយអង្គគត់ដែលបានបញ្ជូនអ្នកនាំសារចុងក្រោយ គឺព្យាការីមូហាំម៉ាត់មកដូចគ្នា។ ដូច្នេះ ជនណាដែលបដិសេធសាររបស់ព្យាការីមូហាំម៉ាត់( សូមសន្តិភាពនិងពរជ័យមានដល់លោក ) ហើយនិយាយថា៖ ខ្ញុំនឹងនៅតែដើរតាមព្យាការីម៉ូសេ ឬព្យាការីយេស៊ូដដែល ជននោះមិនមែនជាអ្នកមានជំនឿឡើយ។

ការនិយាយថា ខ្លួនបានគោរពឱ្យតម្លៃអ្នកមូស្លីម គឺមិនទាន់គ្រប់គ្រាន់សម្រាប់ទទួលបាននូវសេចក្តីសង្គ្រោះនៅថ្ងៃបរលោកនោះទេ។ ហើយការធ្វើទាន និងជួយជនក្រីក្រក៏មិនគ្រប់គ្រាន់ដូចគ្នាដែរ។ ផ្ទុយទៅវិញ ចាំបាច់ត្រូវមានជំនឿចំពោះអល់ឡោះ បណ្តាគម្ពីររបស់ទ្រង់ បណ្តាអ្នកនាំសាររបស់ទ្រង់ និងមានជំនឿចំពោះថ្ងៃបរលោក ទើបអល់ឡោះជាម្ចាស់ទ្រង់ទទួលយកអំពីគេ។ ជាការពិតណាស់ គ្មានបាបកម្មណាដែលធំជាងការគោរពសក្ការៈអ្វីផ្សេងក្រៅពីអលឡោះ ការគ្មានជំនឿចំពោះទ្រង់ និងការបដិសេធសារដែលទ្រង់បានបញ្ចុះមក ឬបដិសេធភាព

ជាអ្នកនាំសារចុងក្រោយរបស់ទ្រង់ គឺព្យាការីមូហាំម៉ាត់ (សូមសន្តិភាពកើតមានដល់លោក)នោះឡើយ។ ដូចនេះ ពួកយូដា និងគ្រីស្តសាសនិកដែលបានឮអំពីការតែងតាំងព្យាការីមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ(សូមសន្តិភាពកើតមានដល់លោក) តែបែរជាបដិសេធមិនមានជំនឿចំពោះលោក និងបដិសេធមិនទទួលយកសាសនាអ៊ីស្លាមនោះ ពួកគេនឹងត្រូវស្ថិតក្នុងឋាននរកជាអមតៈ ដូចដែលអល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖

"ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿក្នុងចំណោមពួកគម្ពីរជន(យូដា និងគ្រីស្ទាន) និងពួកពហុទេពនិយម គឺស្ថិតក្នុងនរកជើហាន់ណាំដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។ ពួកទាំងនោះហើយ គឺជាសត្វលោកដែលអាក្រក់បំផុត"។ [គម្ពីរគួរអាន ៩៨ : ៦]

ដោយសារតែអល់ឡោះជាម្ចាស់ទ្រង់បានបញ្ចុះនូវសារចុងក្រោយមកកាន់មនុស្សជាតិ។ ដូច្នេះ ចាំបាច់លើបុគ្គលគ្រប់រូបដែលបានឮអំពីសាសនាអ៊ីស្លាម និងបានឮអំពីអ្នកនាំសារចុងក្រោយ គឺព្យាការីមូហាំម៉ាត់(សូមសុខសន្តិភាពកើតមានដល់លោក)ត្រូវមានជំនឿលើលោក ដើរតាមមាគ៌ារបស់លោក ហើយត្រូវគោរពតាមបទបញ្ជានិងការហាមប្រាមរបស់លោក។ ជនណាដែលបានឮអំពីសារចុងក្រោយនេះ តែបែរជាបដិសេធចំពោះវានោះ អល់ឡោះជាម្ចាស់នឹងមិនទទួលយកអ្វីមួយពីជននោះឡើយ ហើយទ្រង់ប្រាកដជានឹងដាក់ទណ្ឌកម្មរូបគេនៅថ្ងៃបរលោក។ ក្នុងចំណោមភស្តុតាងដែលបញ្ជាក់ដូចនេះ គឺបន្ទូលរបស់អល់ឡោះជាម្ចាស់ដែលទ្រង់បានមានបន្ទូលថា៖

"ហើយជនណាដែលស្វែងរកសាសនាផ្សេងក្រៅពីអ៊ីស្លាម អល់ឡោះជាម្ចាស់នឹងមិនទទួលយក(ទង្វើល្អ)ពីគេឡើយ ហើយនៅថ្ងៃបរលោក រូបគេនឹងស្ថិតក្នុងចំណោមពួកដែលខាតបង់"។ [គម្ពីរគួរអាន ៣ : ៨៥]

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលទៀតថា៖

“ចូរអ្នក(មូហាំម៉ាត់)ពោលថា៖ ឱពួកគម្ពីរជន(យូដា និងគ្រឹស្ទាន)! ចូរពួកអ្នកត្រឡប់មករកពាក្យសំដីរួមមួយរវាងពួកយើងនិងពួកអ្នក គឺពួកយើងទាំងអស់គ្នាមិនត្រូវគោរពសក្ការៈម្ចាស់ផ្សេងក្រៅពីអល់ឡោះ និងមិនត្រូវធ្វើពហុទេពនិយមនឹងទ្រង់នូវប្រការណាមួយឡើយ ហើយពួកយើងក៏មិនត្រូវយកគ្នាឯងធ្វើជាព្រះផ្សេងពីអល់ឡោះដែរ។ តែប្រសិនបើពួកគេនៅតែបែរចេញ(ពីការអំពាវនាវដ៏ល្អនេះ)ទៀត ចូរពួកអ្នក(អ្នកមានជំនឿ)និយាយទៅកាន់ពួកគេថា៖ ចូរដឹងឮផងថា៖ ពិតប្រាកដណាស់ ពួកយើងគឺជាជនមូស្លីម”។ [គម្ពីរគួរអាន ៣ : ៦៤]

## តើខ្ញុំត្រូវធ្វើម្ដេចដើម្បីក្លាយខ្លួនជាអ្នកមូស្លីម?

ដើម្បីចូលកាន់សាសនាអ៊ីស្លាម ចាំបាច់ត្រូវមានជំនឿលើគោលគ្រឹះនៃជំនឿទាំងប្រាំមួយនេះ៖

- មានជំនឿចំពោះព្រះអល់ឡោះ៖ ជឿថាទ្រង់គឺជាអ្នកបង្កើត ជាអ្នកប្រទានលាភសក្ការៈ ជាអ្នកគ្រប់គ្រង និងជាអ្នកចាត់ចែងគ្រប់យ៉ាង។ គ្មានអ្វីមួយអាចប្រៀបប្រដូចនឹងទ្រង់បានឡើយ។ ទ្រង់គ្មានមហេសី និងគ្មានបុត្រឡើយ ហើយទ្រង់តែមួយអង្គគត់ដែលសក្ដិសមនឹងគោរពសក្ការៈ។
- មានជំនឿចំពោះបណ្ដាទេវតា(ម៉ាឡាអ៊ីកាត់)៖ ជឿថាពួកគេជាខ្ញុំបម្រើរបស់អល់ឡោះ ដែលទ្រង់បានបង្កើតពួកគេពីពន្លឺ។ ពួកគេមានតួនាទីផ្សេងៗគ្នា ដូចជា ទេវតាជីបរ៉ែល(កាព្រីយ៉ែល) មានតួនាទីជាអ្នកនាំសារទៅកាន់ព្យាការីទាំងឡាយរបស់អល់ឡោះ ទេវតាមីកាអែល មានតួនាទីជាអ្នកបញ្ចុះទឹកភ្លៀង និងផ្សេងៗទៀត។

- មានជំនឿចំពោះព្រះគម្ពីរទាំងឡាយរបស់អល់ឡោះដែលទ្រង់បានបញ្ចុះទៅកាន់ព្យាការីទាំងឡាយរបស់ទ្រង់ មានដូចជា គម្ពីរតូរ៉ាឬគម្ពីរសម្ព័ន្ធមេត្រីចាស់ និងអ៊ិញ្ជីលឬគម្ពីរសម្ព័ន្ធមេត្រីថ្មី ហើយនិងគម្ពីរចុងក្រោយ គឺគម្ពីរគួរអាន។
- មានជំនឿចំពោះអ្នកនាំសារទាំងឡាយរបស់អល់ឡោះ ដូចជា ព្យាការីណូអេ អាប្រាហាំ ម៉ូសេ យេស៊ូ ហើយនិងព្យាការីចុងក្រោយ គឺព្យាការីមូហាំម៉ាត់ (សូមសន្តិភាពនិងពរជ័យកើតមានដល់ពួកលោក)។ ពួកលោកគឺជាមនុស្សដែលអល់ឡោះជាម្ចាស់បានពង្រឹងដោយសាររបស់ទ្រង់ និងបានប្រទានដល់ពួកលោកនូវសញ្ញាភស្តុតាង និងអច្ឆរិយភាពជាច្រើនដែលបញ្ជាក់ពីសច្ចៈភាពរបស់ពួកលោក។
- មានជំនឿចំពោះថ្ងៃបរលោក ដោយនៅថ្ងៃនោះ ព្រះអល់ឡោះជាម្ចាស់នឹងប្រោសមនុស្សទាំងអស់ឲ្យរស់ឡើងវិញ ទាំងអ្នកជំនាន់មុន និងជំនាន់ក្រោយ ហើយទ្រង់នឹងកាត់ក្តីរវាងភាវៈរបស់ទ្រង់ទាំងឡាយ។ អ្នកមានជំនឿនឹងបានចូលឋានសួគ៌ ហើយអ្នកគ្មានជំនឿនឹងចូលឋាននរក។
- មានជំនឿលើការកំណត់ព្រេងវាសនា៖ ជឿថា ព្រះអល់ឡោះជាម្ចាស់ដឹងនូវអ្វីៗទាំងអស់ ទាំងអ្វីដែលកើតឡើងក្នុងអតីតកាល និងអ្វីដែលនឹងកើតឡើងនាពេលអនាគត។ ទទួលស្គាល់ថា អល់ឡោះជាអ្នកបង្កើតនូវអ្វីៗទាំងអស់ ដោយទ្រង់បានកត់ត្រា ហើយមានចេតនាឱ្យអ្វីៗទាំងអស់នោះកើតឡើង។

## អ៊ីស្លាម គឺជាមាគ៌ានៃសុភមង្គល

**អ៊ីស្លាម** គឺជាសាសនារបស់មនុស្សជាតិទាំងអស់ ពុំមែនជាសាសនាសម្រាប់តែជនជាតិអារ៉ាប់នោះទេ។

**អ៊ីស្លាម** គឺជាមាគ៌ានៃសុភមង្គលពិតប្រាកដនៅក្នុងលោកិយ អាចដោះស្រាយគ្រប់បញ្ហារបស់មនុស្សជាតិ និងជាបរមសុខជាអមតៈនៅថ្ងៃបរលោក។

“ទ្រង់បានមានបន្ទូលថា៖ ចូរអ្នកទាំងពីរ(អាដាំ និងអេវ៉ា)ចុះចេញពីឋានសួគ៌ទាំងអស់គ្នាចុះ។ ពួកអ្នកមួយចំនួន គឺជាសត្រូវនឹងគ្នា។ ហើយប្រសិនបើការចង្អុលបង្ហាញរបស់យើងមកដល់ពួកអ្នក ជនណាហើយដែលបានដើរតាមការចង្អុលបង្ហាញរបស់យើងនោះ គឺគេមិនវង្វេងឡើយនៅក្នុងលោកិយនេះ ហើយក៏មិនលំបាកនោះដែរនៅថ្ងៃបរលោក។ រីឯជនណាហើយបានងាកចេញពីការដាស់តឿន(នៃគម្ពីរគួរអាន)របស់យើង ពិតប្រាកដណាស់ សម្រាប់គេគឺការរស់នៅយ៉ាងលំបាកវេទនា ហើយយើងនឹងប្រមូលផ្តុំគេនៅថ្ងៃបរលោកក្នុងនាមជាមនុស្សពិការភ្នែក”។ [គម្ពីរគួរអាន ២០ : ១២៣-១២៤]

## តើខ្ញុំទទួលបានផលប្រយោជន៍អ្វីខ្លះពីការចូលសាសនាអ៊ីស្លាម ?

ការចូលសាសនាអ៊ីស្លាម គឺផ្តល់នូវផលប្រយោជន៍ដ៏ធំធេង ក្នុងចំណោមនោះមានដូចជា៖

- ទទួលបាននូវជោគជ័យ និងកិត្តិយសក្នុងលោកិយនេះដោយបានក្លាយជាខ្ញុំបម្រើរបស់ព្រះអល់ឡោះជាម្ចាស់ដែលជាអ្នកបង្កើតរូបគេ។ បើពុំនោះទេនឹងក្លាយជាខ្ញុំបម្រើនៃតណ្ហា បិសាចសាតាំង និងកិលេស។
- ទទួលបាននូវជ័យជម្នះដ៏ធំបំផុតនៅថ្ងៃបរលោក ដោយរួចផុតពីទណ្ឌកម្មនៃភ្លើងនរក ហើយបានចូលឋានសួគ៌ ព្រមទាំងទទួលបានការសព្វព្រះទ័យពីព្រះអល់ឡោះជាម្ចាស់ និងជីវិតអមតៈក្នុងឋានសួគ៌។
- អ្នកដែលត្រូវបានព្រះអល់ឡោះជាម្ចាស់បញ្ចូលទៅក្នុងឋានសួគ៌ ពួកគេនឹងរស់នៅក្នុងបរមសុខជានិច្ច គ្មានការស្លាប់ គ្មានជំងឺ គ្មានការឈឺចាប់ គ្មានទុក្ខព្រួយ និងមិនចាស់នោះឡើយ ហើយពួកគេនឹងទទួលបាននូវអ្វីគ្រប់យ៉ាងដែលពួកគេចង់បាន។

- នៅក្នុងឋានសួគ៌ គឺមានក្ដីរីករាយជាច្រើនដែលភ្នែកមិនធ្លាប់បានឃើញ ត្រចៀកមិនដែលធ្លាប់ឮ ហើយចិត្តមនុស្សក៏មិនធ្លាប់ស្រមៃដល់។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលទៀតថា៖

“ជនណាហើយដែលបានសាងអំពើល្អក្នុងចំណោមបុរស ឬស្ត្រី ហើយគេជាអ្នកមានជំនឿទៀតនោះ គឺយើងពិតជានឹងធ្វើឱ្យគេមានជីវិតរស់នៅដ៏ល្អប្រសើរ ហើយនិងតបស្នងឱ្យពួកគេនូវផលបុណ្យរបស់ពួកគេ ដោយសារតែអំពើល្អដែលពួកគេធ្លាប់បានសាង”។ [គម្ពីរគួរអាន ១៦ : ៩៧]

## តើខ្ញុំនឹងខាតបង់អ្វីខ្លះ ប្រសិនបើខ្ញុំមិនទទួលយកសាសនាអ៊ីស្លាម

- មនុស្សនឹងខាតបង់នូវចំណេះដឹង និងការយល់ដឹងដ៏ធំបំផុត គឺចំណេះដឹង និងការយល់ដឹងពីព្រះអល់ឡោះ។ គេនឹងខាតបង់ជំនឿលើអល់ឡោះដែលជាអ្នកផ្ដល់សុខសន្តិភាព និងភាពស្ងប់ចិត្តនៅក្នុងលោកនេះ និងសុភមង្គលអមតៈនៅថ្ងៃបរលោក។
- មនុស្សនឹងខាតបង់ ប្រសិនបើមិនបានស្វែងយល់ពីព្រះគម្ពីរដ៏ឧត្តុង្គឧត្ដមបំផុតដែលអល់ឡោះជាម្ចាស់ទ្រង់បានបញ្ចុះមកកាន់មនុស្សលោក និងខាតបង់នូវជំនឿចំពោះគម្ពីរដ៏ធំធេងនេះ។
- មនុស្សនឹងខាតបង់នូវជំនឿលើបណ្ដាព្យាការីដ៏ខ្ពង់ខ្ពស់ និងបាត់បង់ឱកាសបាននៅជាមួយពួកលោកនៅក្នុងឋានសួគ៌នាថ្ងៃបរលោក ហើយគេនឹងត្រូវនៅជាមួយពួកបិសាចសាតាំង ពួកឧក្រិដ្ឋជន និងពួកព្រះនានានៅក្នុងឋាននរក ដែលជាទីជម្រកដ៏អាក្រក់ និងជាកន្លែងដ៏ថោកទាបបំផុត។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

“ចូរអ្នក(មូហាំម៉ាត់)ពោលថា៖ ពួកដែលខាតបង់ពិតប្រាកដ គឺពួកដែលបានខាតបង់ខ្លួនឯង និងក្រុមគ្រួសាររបស់ខ្លួននៅថ្ងៃបរលោក។ តើនោះមិនមែនជាការខាតបង់ដ៏ច្បាស់លាស់បំផុតទេឬ? មានភ្លើងជាស្រទាប់ៗនៅពីលើពួកគេ និងនៅពីក្រោមពួកគេ។ (ទណ្ឌកម្ម)នោះហើយដែលអល់ឡោះគំរាមខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ឱ្យភ័យខ្លាច។ ឱខ្ញុំបម្រើទាំងឡាយរបស់យើង! ចូរពួកអ្នកកោតខ្លាចយើងចុះ”។ [គម្ពីរគួរអាន ៣៩ : ១៥-១៦]

## សូមកុំពន្យារពេលក្នុងការធ្វើការសម្រេចចិត្ត!

លោកិយនេះពុំមែនជាកន្លែងអមតៈនោះទេ...

- ភាពស្រស់ស្អាតទាំងអស់នឹងរលាយបាត់ទៅ ហើយភាពត្រេកត្រអាលតាមចំណង់តណ្ហានឹងរលត់ទៅតាមពេលវេលា។
- ថ្ងៃមួយនឹងមកដល់ រូបអ្នកនឹងត្រូវគេជំនុំជម្រះចំពោះអ្វីគ្រប់យ៉ាងដែលអ្នកបានសាង នោះគឺថ្ងៃបរលោក។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

“ហើយសៀវភៅកំណត់ហេតុត្រូវបានគេដាក់(នៅដៃខាងស្តាំសម្រាប់អ្នកដែលមានជំនឿ និងដៃខាងឆ្វេងសម្រាប់អ្នកដែលគ្មានជំនឿ)។ ពេលនោះ អ្នកនឹងឃើញពួកដែលប្រព្រឹត្តអំពើអាក្រក់មានការភ័យខ្លាចនូវអ្វីដែលមាននៅក្នុងកំណត់ហេតុនោះ។ ហើយពួកគេនឹងនិយាយថា៖ វិនាសអន្តរាយហើយពួកយើង! តើនេះជាសៀវភៅកំណត់ហេតុអ្វី បានជាវាមិនបន្សល់ទុកសូម្បីតែអ្វីដែលតូចឬធំ លើកលែងតែវាបានកត់ត្រាទុកទាំងអស់ដូច្នេះ! ហើយពួកគេបានឃើញនៅចំពោះមុខនូវអ្វីដែលពួកគេបានប្រព្រឹត្ត។ ហើយព្រះជាម្ចាស់របស់អ្នកមិនបំពានលើអ្នកណាម្នាក់ឡើយ”។ [គម្ពីរគួរអាន ១៨ : ៤៩]

សាសនាអ៊ីស្លាម ជាសាសនាតែមួយអង្គគត់ដែលព្រះអល់ឡោះជាម្ចាស់ទទួលយក ហើយទ្រង់មិនទទួលយកសាសនាដទៃឡើយ។ ដូចនេះ វាមិនមែនជាការខាតបង់ដែលធម្មតាឡើយ។ ផ្ទុយទៅវិញ វាជាការខាតបង់ដ៏ធំធេងបំផុត។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលទៀតថា៖

“ហើយជនណាដែលស្វែងរកសាសនាផ្សេងក្រៅពីអ៊ីស្លាមនោះ ព្រះអល់ឡោះជាម្ចាស់នឹងមិនទទួលយក(ទង្វើល្អ)ពីគេឡើយ ហើយនៅថ្ងៃបរលោក រូបគេនឹងស្ថិតក្នុងចំណោមពួកដែលខាតបង់”។ [គម្ពីរគួរអាន ៣ : ៨៥]

ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់ជាអ្នកបង្កើតយើង។ យើងនឹងវិលត្រឡប់ទៅកាន់ទ្រង់វិញ។

ត្រូវដឹងថា ឆាកជីវិតលោកិយនេះខ្លីណាស់ ប្រៀបដូចជាសុបិន... ហើយគ្មាននរណាម្នាក់ដឹងថា ខ្លួននឹងស្លាប់នៅពេលណានោះឡើយ។ លោកិយនេះគឺជាការសាកល្បងសម្រាប់យើងប៉ុណ្ណោះ។

ដូចនេះ តើអ្នកនឹងឆ្លើយតបយ៉ាងណាចំពោះព្រះជាម្ចាស់ ប្រសិនបើទ្រង់សួរអ្នកនៅថ្ងៃបរលោកថា៖ ហេតុអ្វីបានជាអ្នកមិនដើរតាមសេចក្តីពិត? ហេតុអ្វីបានជាអ្នកមិនដើរតាមព្យាការីចុងក្រោយ?

តើអ្នកនឹងឆ្លើយតបយ៉ាងណាចំពោះព្រះជាម្ចាស់របស់អ្នកនៅថ្ងៃបរលោក ខណៈដែលទ្រង់បានព្រមានអ្នកអំពីផលវិបាកនៃការបដិសេធនូវសាសនាអ៊ីស្លាម ហើយទ្រង់បានប្រាប់អ្នកថា ជោគវាសនារបស់អ្នកដែលបដិសេធ គឺត្រូវវិនាសក្នុងភ្លើងនរកជាអមតៈនោះ?

“ចំណែកឯពួកដែលប្រឆាំង និងបដិសេធនឹងវាក្យខណ្ឌទាំងឡាយរបស់យើង ពួកទាំងនោះ គឺជាពួកនៃឋាននរក ដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ”។

[គម្ពីរគួរអាន ២ : ៣៩]

## គ្មានលេសដោះសាឡើយសម្រាប់អ្នកដែលបោះបង់ភាពត្រឹមត្រូវ ហើយដើរតាមបុព្វបុរសរបស់ពួកគេដោយងងឹតងងុល

អល់ឡោះបានប្រាប់យើងថា ពិតណាស់ មនុស្សជាច្រើនបានបដិសេធមិនចូលសាសនាអ៊ីស្លាមដោយសារខ្លាចសម្ពាធសង្គមដែលនៅជុំវិញពួកគេ។

មានមនុស្សជាច្រើនបានបដិសេធសាសនាអ៊ីស្លាមព្រោះមិនចង់ផ្លាស់ប្តូរគោលជំនឿដែលខ្លួនមានតាំងពីជីដូនជីតា និងជាប់ជ្រៅនឹងអបិយជំនឿទាំងនោះ។ ហើយមានមនុស្សជាច្រើនទៀតត្រូវបានរារាំងដោយភាពងប់ងុលនឹងប្រការខុសឆ្គងដែលចាក់ឫសយ៉ាងជ្រៅនៅក្នុងខ្លួនរបស់គេ។ អ្នកទាំងនេះ គ្មានលេសដោះសាអ្វីឡើយសម្រាប់ពួកគេចំពោះបញ្ហាទាំងនេះ ហើយពួកគេនឹងត្រូវឈរនៅចំពោះព្រះភក្ត្រព្រះអល់ឡោះជាម្ចាស់ដោយមិនមានអំណះអំណាងអ្វីទាំងអស់។

ការនិយាយអះអាងថា៖ "ការដែលខ្ញុំនៅជាមនុស្សដែលមិនជឿលើព្រះព្រោះខ្ញុំកើតនៅក្នុងគ្រួសារអ្នកដែលមិនជឿលើព្រះ" មិនមែនជាលេសសម្រាប់អ្នកមិនជឿព្រះឡើយ។ ផ្ទុយទៅវិញ គេត្រូវប្រើប្រាជ្ញាដែលព្រះបានប្រទានដើម្បីសង្កេតមើលភាពអស្ចារ្យនៃមេឃា និងផែនដី ហើយត្រូវប្រើគំនិតដែលព្រះបានប្រទានដើម្បីធ្វើការស្វែងយល់ថា សាកលលោកដ៏ធំធេងនេះពិតជាមានអ្នកបង្កើត។ ដូចគ្នានេះដែរ អ្នកដែលគោរពសក្ការៈរូបសំណាក ឬបដិមានានា ក៏គ្មានលេសសម្រាប់ពួកគេចំពោះការធ្វើតាមជីដូនជីតារបស់ខ្លួននោះដែរ។ ផ្ទុយទៅវិញ គេត្រូវស្វែងរកសេចក្តីពិត និងត្រូវសួរខ្លួនឯងថា៖ ហេតុអ្វីខ្ញុំត្រូវគោរពបូជាវត្ថុឥតវិញ្ញាណដែលស្តាប់ខ្ញុំមិនឮ មើលខ្ញុំមិនឃើញ ហើយក៏មិនអាចផ្តល់ផលប្រយោជន៍អ្វីសោះដល់ខ្ញុំបែបនេះ?

ដូច្នេះ អ្នកដែលមានសតិបញ្ញាត្រូវដើរតាមសេចក្តីពិត ហើយមិនត្រូវដើរតាមបុព្វបុរស ឬជីដូនជីតាលើប្រការខុសឆ្គងទាំងងងឹតងងុលឡើយ។

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

“ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកគេ(ពួកគ្មានជំនឿ)ថា៖ ចូរពួកអ្នកត្រឡប់មករកអ្វីដែលអល់ឡោះបានបញ្ចុះ និងមករកអ្នកនាំសារចុះ ពួកគេឆ្លើយថា៖ គ្រប់គ្រាន់ហើយសម្រាប់ពួកយើងនូវអ្វីដែលពួកយើងបានទទួលពីដូនជីតារបស់ពួកយើង។ តើ(ពួកគេនិយាយដូច្នេះ) ទោះបីជាដូនតារបស់ពួកគេគ្មានការយល់ដឹងអ្វីសោះ និងមិនទទួលបានការចង្អុលបង្ហាញក៏ដោយឬ”? [គម្ពីរគួរអាន ៥ : ១០៤]

## តើត្រូវធ្វើដូចម្តេចចំពោះអ្នកដែលចង់ចូលសាសនាអ៊ីស្លាម ប៉ុន្តែព្រួយបារម្ភពីប្រតិកម្មរបស់ក្រុមគ្រួសារ ឬសាច់ញាតិរបស់ខ្លួន?

ចំពោះអ្នកដែលមានបំណងចង់ចូលសាសនាអ៊ីស្លាម ប៉ុន្តែបារម្ភខ្លាចអ្នកជុំវិញខ្លួន គឺគេអាចចូលអ៊ីស្លាម ហើយរក្សាវាជាការសម្ងាត់ រហូតដល់អល់ឡោះសម្រួលនូវផ្លូវដែលល្អសម្រាប់រូបគេដើម្បីអាចរស់នៅដោយឯករាជ្យ និងអាចបើកចំហនូវជំនឿរបស់ខ្លួន។

ដូចនេះ អ្នកចាំបាច់ត្រូវទទួលយកសាសនាអ៊ីស្លាមភ្លាមៗ ប៉ុន្តែអ្នកមិនចាំបាច់ប្រាប់អ្នកជុំវិញខ្លួនថាអ្នកបានចូលអ៊ីស្លាម ឬបង្ហាញវាជាសាធារណៈនោះទេ ប្រសិនបើការធ្វើដូចនោះអាចបង្កគ្រោះថ្នាក់ដល់អ្នក។

អ្នកត្រូវដឹងថា ប្រសិនបើអ្នកចូលកាន់សាសនាអ៊ីស្លាម អ្នកនឹងក្លាយជាបងប្អូននឹងគ្នាជាមួយនឹងអ្នកមូស្លីមរាប់ពាន់លាននាក់ផ្សេងទៀត។ អ្នកអាចទាក់ទងជាមួយវិហារអ៊ីស្លាម ឬមជ្ឈមណ្ឌលអ៊ីស្លាមនៅក្នុងប្រទេសរបស់អ្នកដើម្បីសុំការណែនាំ និងសុំជំនួយ ហើយពួកគេនឹងរីករាយក្នុងការជួយអ្នក។

## មិត្តអ្នកអានជាទីគោរព!

តើការធ្វើឱ្យព្រះអល់ឡោះជាម្ចាស់ដែលជាអ្នកបង្កើតអ្នកសព្វព្រះទ័យ (ដែលទ្រង់ជាអ្នកដែលបានប្រទាននូវឧបការគុណទាំងឡាយដល់អ្នក បានផ្តល់នូវអាហារដល់អ្នក ខណៈដែលអ្នកនៅជាគភ៌ក្នុងផ្ទៃម្តាយ និងផ្តល់ខ្យល់ឱ្យអ្នកដកដង្ហើមនាពេលនេះ) មិនសំខាន់ជាងការធ្វើឲ្យអ្នកដទៃពេញចិត្តចំពោះអ្នកទេឬ?

តើការទទួលបានជោគជ័យទាំងក្នុងលោកិយនេះ និងនៅថ្ងៃបរលោក មិនសក្តិសមនឹងការលះបង់នូវភាពសប្បាយបណ្តោះអាសន្ននៃជីវិតនេះទេឬ?

សូមកុំឱ្យអតីតកាលរបស់អ្នករារាំងអ្នកពីការកែតម្រូវនូវផ្លូវដែលអ្នកធ្លាប់ដើរខុស ហើយទទួលយកនូវអ្វីដែលត្រឹមត្រូវ។

ចូរក្លាយជាអ្នកដែលមានជំនឿពិតប្រាកដនៅថ្ងៃនេះ ហើយកុំឱ្យបិសាចសាតាំងរារាំងអ្នកអំពីការដើរតាមសេចក្តីពិត និងភាពត្រឹមត្រូវ!

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

“ឱមនុស្សលោកទាំងឡាយ! សញ្ញាភស្តុតាងពីព្រះជាម្ចាស់របស់ពួកអ្នកពិតជាបានមកដល់ពួកអ្នកហើយ។ ហើយយើងបានបញ្ចុះទៅកាន់ពួកអ្នកនូវពន្លឺយ៉ាងច្បាស់(ព្រះគម្ពីរគួរអាន)។ រីឯបណ្តាអ្នកដែលមានជំនឿចំពោះអល់ឡោះ ហើយប្រកាន់ខ្ជាប់នឹងគម្ពីរគួរអាននោះ ទ្រង់នឹងបញ្ចូលពួកគេទៅក្នុងឋានសួគ៌ដោយក្តីមេត្តាករុណានិងការប្រោសប្រទានពីទ្រង់ ព្រមទាំងចង្អុលបង្ហាញពួកគេនូវមាគ៌ាដ៏ត្រឹមត្រូវ”។ [គម្ពីរគួរអាន ៤ : ១៧៤-១៧៥]

## តើអ្នកបានត្រៀមខ្លួនហើយឬនៅ ដើម្បីធ្វើការសម្រេចចិត្តដ៏ធំបំផុតក្នុងជីវិតរបស់អ្នក?

ប្រសិនបើអ្វីដែលបានលើកឡើងខាងលើនេះមានហេតុផលច្បាស់លាស់សមហេតុផលសម្រាប់អ្នក ហើយអ្នកទទួលស្គាល់ការពិតនៅក្នុងចិត្តរបស់អ្នករួចហើយនោះ អ្នកត្រូវតែបោះជំហានដំបូងដើម្បីឆ្ពោះទៅមុខក្លាយជាជនមូស្លីម។ តើអ្នកអាចអនុញ្ញាតឱ្យខ្ញុំជួយដល់ការសម្រេចចិត្តដ៏ល្អបំផុតនៅក្នុងជីវិតរបស់អ្នក និងណែនាំអ្នកអំពីរបៀបដើម្បីក្លាយជាអ្នកមូស្លីមឬទេ?

ចូរកុំឱ្យអំពើបាបរបស់អ្នករារាំងអ្នកពីការចូលកាន់សាសនាអ៊ីស្លាម ព្រោះអល់ឡោះជាម្ចាស់ទ្រង់បានប្រាប់យើងនៅក្នុងគម្ពីរគួរអានថា ជាការពិតណាស់ទ្រង់នឹងអត់ទោសឱ្យចំពោះអំពើបាបទាំងអស់របស់មនុស្ស ប្រសិនបើគេទទួលយកសាសនាអ៊ីស្លាម និងប្រែចិត្តត្រឡប់ទៅរកព្រះជាម្ចាស់ដែលជាអ្នកបង្កើត។ សូម្បីតែបន្ទាប់ពីអ្នកទទួលយកសាសនាអ៊ីស្លាមហើយក៏ដោយ វាជារឿងធម្មតាទេដែលអ្នកនឹងនៅតែប្រព្រឹត្តអំពើបាបខ្លះ ព្រោះយើងជាមនុស្ស មិនមែនជាទេវតាដែលគ្មានកំហុសនោះឡើយ។ ប៉ុន្តែអ្វីដែលតម្រូវឱ្យយើងធ្វើ គឺសុំការលើកលែងទោសពីអល់ឡោះ និងប្រែចិត្តទៅរកទ្រង់។ ប្រសិនបើអល់ឡោះឃើញថា អ្នកជាមនុស្សដែលរួសរាន់ក្នុងការទទួលយកភាពត្រឹមត្រូវ ហើយបានចូលកាន់សាសនាអ៊ីស្លាម និងពោលពាក្យសក្ខីកម្ម(ស្ហាហាហ្ទះ) នោះទ្រង់នឹងជួយអ្នកឱ្យបោះបង់អំពើបាបផ្សេងៗទៀត។ អ្នកដែលបែរមករកអល់ឡោះ និងដើរតាមសេចក្តីពិតនោះអល់ឡោះជាម្ចាស់នឹងប្រទាននូវប្រការល្អដល់គេកាន់តែច្រើនបន្ថែមទៀត។ ដូច្នេះ ចូរកុំស្ទាក់ស្ទើរចិត្តក្នុងការទទួលយកសាសនាអ៊ីស្លាមក្នុងពេលឥឡូវនេះ!

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖
“ចូរអ្នក(មូហាំម៉ាត់)ពោលទៅកាន់ពួកដែលគ្មានជំនឿថា ប្រសិនបើពួកគេបញ្ឈប់ការប្រឆាំងនឹងអល់ឡោះនោះ គេនឹងអភ័យទោសឱ្យពួកគេនូវអ្វីដែលពួកគេបានប្រព្រឹត្តកន្លងមក”។ [គម្ពីរគួរអាន ៨ : ៣៨]

## ដើម្បីក្លាយខ្លួនជាអ្នកមូស្លីម តើខ្ញុំត្រូវធ្វើដូចម្តេច?

ការចូលកាន់សាសនាអ៊ីស្លាម គឺជារឿងងាយស្រួល ហើយមិនតម្រូវឱ្យមានកិច្ចពិធីធំដុំ ឬនីតិវិធីផ្លូវការណាមួយ ឬក៏តម្រូវឱ្យមានអ្នកណាម្នាក់ចូលរួមនោះឡើយ។ គេគ្រាន់តែពោលពាក្យសក្ខីកម្ម(ស្ហាហាហ្ទះ)ទាំងពីរឃ្លា ដោយយល់ច្បាស់ពីអត្ថន័យនៃពាក្យនេះ និងមានជំនឿលើវាប៉ុណ្ណោះ ដោយអ្នកត្រូវពោលថា៖ “អាស្ហហាទូ អាល់ឡា អ៊ីឡាហា អ៊ិលលល់ឡោះ វ៉ាអាស្ហហាទូ អាន់ណា មូហាំម៉ាតាន់ រ៉ស៊ូលុលឡោះ” ដែលមានន័យថា៖ “ខ្ញុំសូមធ្វើសាក្សីថា គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះនោះឡើយ ហើយខ្ញុំសូមធ្វើសាក្សីទៀតថា មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ”។

ប្រសិនបើអ្នកអាចពោលវាជាភាសាអារ៉ាប់បាននោះជាការល្អ។ តែប្រសិនបើវាពិបាកសម្រាប់អ្នក អ្នកអាចពោលវាជាភាសារបស់អ្នកបាន។ តាមរយៈការពោលពាក្យទាំងពីរឃ្លានេះរួច គឺអ្នកបានក្លាយជាជនមូស្លីមហើយ។ បន្ទាប់មកចាំបាច់លើអ្នកត្រូវសិក្សាអំពីសាសនាអ៊ីស្លាមដែលនឹងក្លាយជាប្រភពនៃសុភមង្គលរបស់អ្នកក្នុងលោកិយនេះ និងជាការសង្គ្រោះសម្រាប់អ្នកនៅថ្ងៃបរលោក។

តំណភ្ជាប់ទៅកាន់សេចក្តីប្រែសម្រួលអត្ថន័យនៃគម្ពីរគួរអាន៖

តំណភ្ជាប់ទៅកាន់សេចក្តីប្រែសម្រួលអត្ថន័យនៃហាទីស្ហ៖

សម្រាប់ព័ត៌មានបន្ថែមអំពីសាសនាអ៊ីស្លាម
សូមចូលទៅកាន់គេហទំព័រ៖



អង្គការវប្បធម៌ អារ្យធម៌ កម្ពុជា-អារ៉ាប់
المركز الثقافي
الحضاري العربي - كمبوديا
Cambodia Arab Cultural Civilizational Organization

បោះពុម្ពផ្សាយដោយ

**អង្គការវប្បធម៌ អារ្យធម៌ កម្ពុជា-អារ៉ាប់**